**Probate and Family Court**
**អាណត្តិភ័យចិន្ត្រ្គយ៍ 2 – 20 ដូចបានធ្វើវិសោធនកម្មថ្ងៃទី 6 ខែមេសា ឆ្នាំ 2020**
**ប្រតិបត្តិការតុលាការក្នុងកាលៈទេសៈបន្ទាន់ដែលបណ្តាលមកពីកូវីដ-19**

ដោយសារហានិភ័យខ្លាំងបំផុតនៃការឆ្លងពីមនុស្សទៅមនុស្សដែលបណ្តាលមកពីមេរោគកូរ៉ូណាថ្មី ឆ្នាំ 2019 "COVID-19" ដែលត្រូវបានគេប្រកាសថា ជាការរាតត្បាតឆ្លងថ្មីបដោយអង្គការសុខភាពពិភពលោកហើយដែលបាននាំឱ្យមានការប្រកាសពីភាពអាសន្នមួយទូទាំងរដ្ឋនៃរដ្ឋម៉ាស្សាជូសេត្ស៍ បទបញ្ជានីតិប្រតិបត្តិលេខ 591៖ សេចក្តីប្រកាសស្តីពីភាពអាសន្នទូទាំងរដ្ឋដើម្បីឆ្លើយតបទៅនឹងកូវីដ-19 និងទូទាំងប្រទេសប្រកាសដោយប្រធានាធិបតីសហរដ្ឋអាមេរិក និងបញ្ជារបស់តុលាការកំពូលលេខ OE-144, ខ្ញុំសូមប្រកាសប្រើសិទ្ធិអំណាចដែលផ្តល់ឱ្យខ្ញុំតាមច្បាប់ G. L. c. 211B, § 10 ប្រកាសឱ្យអនុវត្តអាណត្តភ័យចិន្ត្រ្គយ៍នេះ ដើម្បីការពារសុខភាពសាធារណៈដោយកាត់បន្ថយហានិភ័យនៃការប៉ះពាល់នឹងមេរោគ និងពន្យឺតការរីករាលដាលនៃជំងឺ។

ដើម្បីរក្សាភាពស្ថិតស្ថេរក្នុងចំណោមស្ថាប័ននៃតុលាការផ្នែកមរតក និងគ្រួសារ អាណត្តិភ័យចិន្ត្រ្គយ៍នេះនឹងជំនួសពិធីសាររដ្ឋបាល ឬកាលវិភាគនានាដែលត្រូវបានគេបង្កើតពីមុនដោយផ្នែកណាមួយនៃស្ថាប័ននៃតុលា ការផ្នែកមរតក និងគ្រួសារ ដើម្បីឆ្លើយតបទៅនឹងកូវីដ-19 ក៏ដូចជាអាណត្តិភ័តចិន្ត្រ្គយ៍លេខ 1 – 20។

ដូច្នេះត្រូវ**ចេញបញ្ជា**ដូចតទៅ ចាប់ផ្តើមមានប្រសិទ្ធិភាពពីថ្ងៃទី6 ខែមេសា ឆ្នាំ2020 នៅចន្លោះម៉ោងធ្វើការធម្មតាពីម៉ោង 8:30ព្រឹក និងម៉ោង 4:30 ល្ងាច ស្ថាប័ននៃតុលាការផ្នែកមរតក និងគ្រួសារ នឹងប្រតិបត្តិតាមល័ក្ខខ័ណ្ឌបន្ទាន់បណ្តោះអាសន្នដូចតទៅ។ យ៉ាងហោចណាស់រហូតដល់ថ្ងៃទី 4 ខែឧសភា ឆ្នាំ2020 តុលាការផ្នែកមរតកនិងគ្រួសារ នឹងនៅបើកទ្វារសម្រាប់តែដោះស្រាយបញ្ហាបន្ទាន់ណាដែលមិនអាចត្រូវបានដោះស្រាយបានពីចម្ងាយ (ឧទាហរណ៍ ដូចជាតាមទូរស័ព្ទ តាមការជួបរយៈវីឌីអូ អ៊ីមែល ឬមធ្យោបាយស្រដៀងគ្នាដទៃ ឬតាមរយៈប្រព័ន្ធដាក់ឯកសារអេឡិចត្រូនិក) ដោយសារវាមិនអាចអនុវត្តបាន ឬក៏មិនស្របនឹងការការពារសិទ្ធិតាមច្បាប់រដ្ឋធម្មនុញ្ញ។ ការិយាល័យតម្កល់ឯកសារនឹងបន្តដំណើរការកិច្ចការតុលាការ ពោលគឺ ការទទួលការដាក់បណ្តឹង និងឯកសារផ្សេងទៀតក្នុងករណីបន្ទាន់ រៀបចំកាលវិភាគ និងសម្រួលដល់សវនាការក្នុងរឿងបន្ទាន់ ចេញបញ្ជាសម្រាប់ករណីចាំបាច់ ឆ្លើយសំណួរពីមេធាវី គូបណ្តឹង និងសាធារណជនទូទៅ និងចាត់ការកិច្ចការចាំបាច់នានាពីតុលាការដទៃទៀត។ កិច្ចការទាំងអស់នោះនឹងត្រូវធ្វើឡើងពីចម្ងាយ លើកលែងតែពេលដាក់ពាក្យបណ្តឹង និងឯកសារផ្សេងទៀតនៅក្នុងករណីបន្ទាន់ដែលមិនអាចត្រូវបានគេធ្វើកើតពីចម្ងាយ។ ករណីបន្ទាន់នោះត្រូវរៀបរាប់នៅក្នុងវគ្គ B, វគ្គ C (3) វគ្គ E និងវគ្គ F (1), (2) និង (3) នៃអាណត្តិភ័យចិន្ត្រ្គយ៍នេះ។ ក្រៅពីការលើកលែងដែលមានចែងក្នុងវគ្គ C (2) ការចូលទៅក្នុងតុលាការសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីជាបន្ទាន់ដោយផ្ទាល់នឹងត្រូវមានកំណត់ត្រឹមមេធាវី ភាគី សាក្សី និងអ្នកដែលចាំបាច់ផ្សេងទៀត ដូចដែលបានសម្រេចដោយចៅក្រមដែលគេបានចាត់តាំង រួមទាំងមិនលើសពីសមាជិកបីនាក់នៃ "អ្នកយកសារព័ត៌មាន" ដូចដែលបានកំណត់នៅក្នុងវិធាន 1:19(2) របស់តុលាការកំពូល។

**A. តាមទូរស័ព្ទ/ជួបតាមវីឌីអូ/សវនាការ "ប្រយោលឬពីចម្ងាយ"**

នៅពេលណាដែលសមហេតុផល និងអាចធ្វើទៅបាន តុលាការនឹងបើកសវនាការតាមទូរស័ព្ទ ឬជួបតាមវីឌីអូ ជាជាងឱ្យបុគ្គលមកបង្ហាញខ្លួនដោយផ្ទាល់ ឬរើសថ្ងៃថ្មីសម្រាប់សំណុំរឿងនោះ។

**B. បញ្ជាហាមឃាត់យោងតាមច្បាប់ G. L. c. 209A/បញ្ជាចុះចេញយោងតាមច្បាប់ G. L. c. 208, § 34B**

1. ការស្នើសុំបញ្ជាហាមឃាត់ទាំងអស់ និងការស្នើឱ្យចេញបញ្ជាឱ្យចុះចេញចាត់ទុកថាជាករណីជាបន្ទាន់ ហើយថ្ងៃដែលពួកគេត្រូវត្រឡប់មកវិញពីដំបូង រួមទាំងថ្ងៃត្រូវត្រឡប់មកវិញនៅពេលការជូនដំណឹងពុំទាន់បានបំពេញសម្រេចនឹងត្រូវតុលាការទទួលស្តាប់តាមទូរស័ព្ទ ឬជួបតាមវីឌីអូ។

2. រាល់បទបញ្ជាការពារបន្ទាន់ទាំងអស់ (G. L. c. 209A; G. L. c. 208, § 34B) ត្រូវបានចេញក្នុងសវនាការបន្ទាប់ពីការជូនដំណឹងមុនការចេញអាណត្តិភ័យចិន្ត្រៃយ៍នេះ ហើយដែលនឹងត្រូវផុតកំណត់នៅថ្ងៃទី 16 ខែមីនា ឆ្នាំ 2020 នឹងនៅតែមានប្រសិទ្ធិភាពរហូតទាល់តែសំណុំរឿងនោះត្រូវគេកំណត់ថ្ងៃថ្មី ហើយតុលាការផ្ទេកមរតក និងគ្រួសារបានស្តាប់សំណុំរឿងនោះ។

3. បញ្ជាសុំឱ្យមានការការពារណា (G. L. c. 209A; G. L. c. 208, § 34B) ដែលគេបានចេញឱ្យនៅក្នុងសវនាការបន្ទាប់ពីការជូនដំណឹងក្នុងអំឡុងពេលនៃអាណត្តិភ័យចិន្ត្រៃយ៍ ដែលតុលាការបានស្តាប់ដោយមិនមានវត្តមានសាមីខ្លួនដោយផ្ទាល់នឹងអាចត្រូវបានចេញតែរហូតដល់ថ្ងៃដែលតុលាការអាចធ្វើសវនាការដោយមានសាមីខ្លួនចូលរួមផ្ទាល់។

## C. ប្រភេទសំណុំរឿង និងព្រឹត្តិការណ៍ជាក់លាក់

1. រាល់ព្រឹត្តិការណ៍សំណុំរឿងដែលបានគ្រោងទុករួចហើយនឹងត្រូវបន្តទៅថ្ងៃណាមួយបន្ទាប់ពីថ្ងៃទី 4 ខែឧសភា ឆ្នាំ2020 លើកលែងតែ បើពុំដូច្នោះទេ ត្រូវបានគេបញ្ជាក់ផ្សេងពីនេះនៅក្នុងវគ្គ B និងវគ្គ E។

2. ការជំនុំជម្រះដែលមិនទាន់បានចាប់ផ្តើមនឹងត្រូវបន្តទៅក្រោយថ្ងៃទី 4 ខែឧសភា ឆ្នាំ2020 លើកលែងតែការជំនុំជម្រះនោះអាចធ្វើទៅបានដោយវិធីផ្សេងជាជាងមានវត្តមានរបស់សាមីខ្លួន ហើយដោយមានការយល់ព្រមពីភាគីទាំងអស់ និងដោយតុលាការ។ នៅពេលដែលការជំនុំជម្រះបានចាប់ផ្តើម ការសម្រេចថាតើការជំនុំជម្រះក្តីគួរដំណើរការទៅមុខ និងដោយរបៀបណា នឹងអាស្រ័យតាមការពិចារណាសមហេតុផលរបស់ចៅក្រមជំនុំជម្រះ ដោយមានការពិគ្រោះយោបល់ជាមួយប្រធានចៅក្រមនៃតុលា ការមរតក និងគ្រួសារ។ ប្រសិនបើការជំនុំជម្រះក្តីដែលនៅព្យួរទុកនោះនឹងត្រូវធ្វើឡើង នោះវានឹង ត្រូវគេចាត់ទុកថាជាបញ្ហាបន្ទាន់ ហើយការចូលរួមក្នុងការជំនុំជម្រះបែបនេះនឹងត្រូវបានគេដាក់កម្រិតសម្រាប់តែបុគ្គលដែលចាំបាច់ដូចបានចែងខាងលើ រួមទាំងមិនលើសពីសមាជិកសាធារណៈ ឬ"សារព័ត៌មាន" ចំនួនដប់នាក់ ដែលនឹងត្រូវទទួលឱ្យចូល តាមគោលការអ្នកណាមកដល់មុន ហើយនឹងអង្គុយមិនជិតជាងប្រាំមួយហ្វីតពីគ្នា ឬពីអ្នកដទៃ។

3. បន្ទាប់ពីការបង្ហាញនៃកាលៈទេសៈពិសេស/បន្ទាន់ ភាគីដែលមានការជំនុំជម្រះក្តី ឬសវនាការទាក់ទងភស្តុតាងដែលត្រូវបានពន្យារពេលដោយអាណត្តិភ័យចិន្ត្រៃយ៍នេះ អាចស្នើសុំឱ្យមានការលើកលែងពីអាណត្តិភ័យចិន្ត្រៃយ៍នេះដោយដាក់ញត្តិដែលនឹងត្រូវតុលាការស្តាប់តាមសេចក្តីថ្លែងសំអាង ឬតាមទូរស័ព្ទ។ គ្មានការលើកលែងណាដែលនឹងត្រូវគេអនុញ្ញាតឡើយ លើកលែងតែមានការយល់ព្រមពីចៅក្រមដែលគេបានចាត់តាំង និងប្រធានចៅក្រមនៃតុលាការផ្ទេកមរតក និងគ្រួសារ។

4. នៅពេលដែលការជំនុំជម្រះក្តី ឬសវនាការទាក់ទងភ័ស្តុតាងត្រូវបានគេពន្យាពេលដោយសារតែអាណត្តិភ័យចិន្ត្រៃយ៍នេះ ភាគីអាចស្នើឱ្យមានការជួបជាមួយតុលាការដើម្បីពិភាក្សាពីបញ្ហាដែលកើតឡើងដោយសារការពន្យាពេល ដែលនឹងត្រូវធ្វើឡើងតាមទូរស័ព្ទ ឬជួបតាមវីឌីអូ។

## D. ការដាក់ឯកសារសំណុំរឿងថ្មី

លើកលែងតែបញ្ហាហ្នឹងត្រូវគេចាត់ទុកថាជាការសំខាន់ និងចាំបាច់ឱ្យមានការចាត់វិធានការពីតុលាការ ភាគីទាំងអស់ត្រូវដាក់ឯកសារសំណុំរឿងថ្មីតាមសំបុត្រ អ៊ីមែល ឬឯកសារតាមអនឡាញ។ ការដាក់ឯកសារនោះនឹងត្រូវគេប្រគល់លេខសំណុំរឿង ប៉ុន្តែនឹងមិនមានព្រឹត្តិការណ៍ណាត្រូវគេកំណត់មុនថ្ងៃទី 5 ខែឧសភា ឆ្នាំ2020 ឡើយ។

**E.** **ប្រភេទសំណុំរឿង និងព្រឹត្តិការណ៍បន្ទាន់**

ស្ថានភាពបន្ទាន់ណាដែលមិនបានបញ្ជាក់ខាងក្រោម ឬក្នុងវគ្គ B ខាងលើនឹងត្រូវគេពិចារណាដោយផ្អែកតាមលេខរៀងសំណុំរឿង។ ប្រសិនបើមនុស្សម្នាក់ទៅដល់តុលាការដោយមានបញ្ហាដែលគេយល់ថាជារឿងបន្ទាន់ បញ្ហានោះនឹងត្រូវបញ្ជូនទៅអ្នកចាត់ចែងសំណុំរឿងតុលាការ ជំនួយការអ្នកចាត់ចែងសំណុំរឿងតុលាការ ជំនួយការបញ្ជិកា ចៅក្រមថ្នាក់ក្រោម ឬបុគ្គលិកគេជ្រើសទុកជាមុនដទៃទៀត ដើម្បីសម្រេច ថាតើបញ្ហាហ្នឹងវាបន្ទាន់ ឬបុគ្គលហ្នឹងអាចត្រូវគេជួយតាមវិធីផ្សេង។

ប្រភេទសកម្មភាព/ករណីខាងក្រោមត្រូវបានកំណត់ថាជាបញ្ហាបន្ទាន់ ហើយនឹងអាចដាក់ក្រដាសស្នាមបាន ហើយនឹងត្រូវតុលាការស្តាប់ លើកលែងតែតុលាការតម្រូវឱ្យមានការជូនដំណឹងជាមុនៈ

1. បង្គនាលិខិត/ញត្តិស្នើសុំបញ្ជាកុំធ្វើឱ្យដឹងខ្លួនឡើងវិញ/កុំស៊កបំពង់/ប្រើវិធីសាស្ត្រធ្វើឱ្យបានស្រួលប៉ុណ្ណោះ(DNR/DNI/CMO), បញ្ជាការអនុញ្ញាតសម្រាប់ការព្យាបាល ឬបញ្ជាសម្រាប់ថ្នាំប្រឆាំងនឹងរោគផ្លូវចិត្ត;
2. បង្គនាលិខិតស្នើសុំឱ្យមានការតែងតាំងអាណាព្យាបាល ឬអភិរក្សជាបណ្តោះអាសន្ន;
3. បង្គនាលិខិតយោងតាមច្បាប់ G. L. c. 19A, § 7 និង G. L. c. 19C, § 20 – សេវាកម្មការពារ;
4. ការសម្រេចតំណាងផ្នែករក្សាសុខភាព;
5. បង្គនាលិខិត/ញត្តិសម្រាប់ឱ្យមានការតែងតាំងតំណាងពិសេសផ្ទាល់ខ្លួន;
6. បង្គនាលិខិតសម្រាប់ការរៀបអាពាហ៍ពិពាហ៍ដោយមិនមានការបង្អង់;
7. បណ្តឹងសម្រាប់ការនៅក្រោមអាណាព្យាបាល (SIJS) បើកូននឹងមានអាយុ 21ឆ្នាំមុនថ្ងៃទី 5 ខែឧសភា ឆ្នាំ 2020;
8. រាល់ការស្នើសុំទាំងអស់សម្រាប់ការបង្គាប់ឱ្យមានការបន្ធូរបន្ថយ;
9. ញត្តិសម្រាប់បញ្ជាបណ្តោះអាសន្ន ដែលស្ថានភាពពិសេស/បន្ទាន់ត្រូវបានបង្ហាញឱ្យឃើញ; និង
10. ការសម្រេចលើការប្រព្រឹត្តល្មើស ដែលស្ថានភាពពិសេស/បន្ទាន់ត្រូវបានបង្ហាញឱ្យឃើញ។

**F.** **ការបន្តនៃបញ្ជាបន្ថែម**

1. បញ្ជាអាណាព្យាបាលចេញដោយចៅក្រមទៅក្រសួងកុមារនិងគ្រួសារដោយយោងតាមច្បាប់ G.L. c. 119A, § 23 (a) (3) ដែលផុតកំណត់នៅចន្លោះថ្ងៃទី 18 ខែមីនា ឆ្នាំ2020 និងថ្ងៃទី 4 ខែឧសភា ឆ្នាំ 2020 នឹងត្រូវបន្តតាមវិធីរដ្ឋបាលរយៈពេល 45 ថ្ងៃ ចាប់ពីថ្ងៃផុតកំណត់។ ដោយមានមូលហេតុល្អ ភាគីមួយអាចស្នើឱ្យគេយកសំណុំរឿងមកមុនពេលវេលា បន្ទាប់ពីមានការបង្ហាញពីស្ថានភាពបន្ទាន់។ សំណើអាចនឹងត្រូវគេសម្រេចអាស្រ័យតាមសេចក្តីថ្លែងសំអាង។

2. បញ្ជាទាក់ទងនឹងគម្រោងព្យាបាលដែលផុតកំណត់នៅចន្លោះថ្ងៃទី 18 ខែមីនា ឆ្នាំ 2020 និងថ្ងៃទី 4 ខែឧសភា ឆ្នាំ 2020 នឹងត្រូវពន្យាតាមរដ្ឋបាលរយៈពេល 60ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់។ ដោយមានមូលហេតុល្អ ភាគីមួយអាចស្នើឱ្យគេយកសំណុំរឿងមកមុនពេលវេលា បន្ទាប់ពីមានការបង្ហាញពីស្ថានភាពបន្ទាន់។ សំណើអាចនឹងត្រូវគេសម្រេចអាស្រ័យតាមសេចក្តីថ្លែងសំអាង។

3. បញ្ជាបណ្តោះអាសន្នក្នុងការតែងតាំងអាណាព្យាបាល និងអ្នកអភិរក្សដែលផុតកំណត់នៅចន្លោះថ្ងៃទី 18 ខែមីនា ឆ្នាំ2020 ដល់ថ្ងៃទី 4 ខែឧសភា ឆ្នាំ 2020 នឹងត្រូវបន្តតាមរដ្ឋបាលរយៈពេល 60 ថ្ងៃ ចាប់ពីថ្ងៃផុតកំណត់។ ដោយមានមូលហេតុល្អ ភាគីមួយអាចស្នើឱ្យគេយកសំណុំរឿងមកមុនពេលវេលា បន្ទាប់ពីមានការបង្ហាញពីស្ថានភាពបន្ទាន់។ សំណើអាចនឹងត្រូវគេសម្រេចអាស្រ័យតាមសេចក្តីថ្លែងសំអាង។

4. រាល់បញ្ជាទាំងអស់ដែលត្រូវបានគេចេញមុនអាណត្តិភ័យចិន្ត្រៃយ៍នេះ និងបន្ទាប់ពីសវនាការជំទាស់ (ឬឱកាសសម្រាប់សវនាការជំទាស់) ដែលផុតកំណត់មុនថ្ងៃទី 4 ខែឧសភា ឆ្នាំ 2020 នឹងនៅតែមានសុពលភាពរហូតដល់សំណុំរឿងនោះត្រូវបានរើសថ្ងៃជាថ្មី និងតុលាការបានស្តាប់។

**G.** អាណត្តិភ័យចិន្ត្រៃយ៍នេះមិនប៉ះពាល់ដល់សមត្ថភាពរបស់តុលាការផ្នែកមរតកនិងគ្រួសារក្នុងការពិចារណាលើសំណុំរឿងដែលអាចត្រូវគេដោះស្រាយបានដោយមិនចាំបាច់មាននីតិវិធីដែលមានវត្តមានផ្ទាល់របស់បុគ្គលតាមរយៈការទាក់ទងដោយទូរស័ព្ទ ជំនួបប្រជុំតាមវីដីអូ អ៊ីមែល ឬមធ្យោបាយផ្សេងទៀតដែលអាចប្រៀបធៀបបានឡើយ។

**H. កម្មវិធីនានា**

1. តម្រូវការការអប់រំសម្រាប់មាតាបិតាត្រូវបានគ្រប់គ្រងដោយការធ្វើវិសោធនកម្មជាបណ្ដោះអាសន្នអាស្រ័យតាមអណត្តិភ័យចិន្ត្រៃយ៍ 2-16: ការចូលរួមកម្មវិធីអប់រំសម្រាប់មាតាបិតា។

2. កម្មវិធីមេធាវីប្រចាំថ្ងៃនឹងមិនត្រូវបានគេធ្វើឡើងឡើយរហូតដល់ថ្ងៃទី 4 ខែឧសភា ឆ្នាំ2020 លើកលែងតែអាចធ្វើទៅបានពីចម្ងាយ។

3. បុគ្គលណាដែលត្រូវបានគេបញ្ជាឱ្យបំពេញសេវាកម្មការងារសហគមន៍នឹងមិនចាំបាច់ត្រូវធ្វើការងារសហគមន៍នោះរហូតដល់បន្ទាប់ពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2020 ។

**I. ការធ្វើវិសោធនកម្ម និងការបន្តនៃអាណត្តិភ័យចិន្ត្រៃយ៍ 2 – 20 ដូចដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី 6 ខែមេសា ឆ្នាំ 2020**

តុលាការផ្នែកមរតកនិងគ្រួសារនឹងធ្វើវិសោធនកម្មអនុញ្ញាតឱ្យផុតកំណត់ ឬពន្យារពេលអាណត្តិភ័យចិន្ត្រៃយ៍នេះមិនឱ្យហួសពីថ្ងៃទី 4 ខែឧសភា ឆ្នាំ2020ឡើយ។

<u>ថ្ងៃទី 3 ខែមេសា 2020</u>
ចេញថ្ងៃ

<u>/s/ John D. Casey</u>
John D. Casey
ប្រមុខចៅក្រម
តុលាការផ្នែកមរតក និងគ្រួសារ